クメール語（カンボジア）：ゆうちょ銀行とお取引をされる外国人のお客さまへ

# ចំពោះអតិថិជនជាជនបរទេសដែលធ្វើប្រតិបត្តិការជាមួយ ធនាគារប្រៃសណីយ៍ជប៉ុន

■ <u>សូមបង្ហាញប័ណ្ណស្នាក់នៅនៅពេលបើកគណនី ផ្លាស់ប្តូរអាសយដ្ឋាន/ឈ្មោះ ពេលកែប្រែត្រា។</u>

ដើម្បីពិនិត្យសញ្ជាតិ/លក្ខណៈសម្បត្តិនៃការស្នាក់នៅ/រយៈពេលស្នាក់នៅជាដើម សូមបង្ហាញប័ណ្ណស្នាក់នៅ។

* ករណីបានពន្យារប័ណ្ណស្នាក់នៅ សូមជូនដំណឹងនៅពេលធ្វើបែបបទ។

* ចំពោះអ្នកដែលមិនត្រូវបានផ្តល់ជូនប័ណ្ណស្នាក់នៅដោយសារជាមន្ត្រីការទូតជាដើម មិនចាំបាច់បង្ហាញទេ។

■ <u>ករណីថ្ងៃផុតកំណត់រយៈពេលស្នាក់នៅនឹងមកដល់ក្នុងរង្វង់ 3 ខែគិតពីថ្ងៃដាក់ពាក្យសុំបើកគណនី សូមដាក់ពាក្យសុំបន្ទាប់ពីបញ្ចប់ការធ្វើបែបបទពន្យាររយៈពេលស្នាក់នៅ។</u>

ករណីថ្ងៃផុតកំណត់រយៈពេលស្នាក់នៅនឹងមកដល់ក្នុងរង្វង់ 3 ខែគិតពីថ្ងៃដាក់ពាក្យសុំបើកគណនី យើងមិនអាចបើកគណនីជូនបានឡើយ។

អតិថិជនដែលគ្រោងស្នាក់នៅបន្ត សូមដាក់ពាក្យសុំបើកគណនីបន្ទាប់ពីធ្វើបែបបទពន្យាររយៈពេលស្នាក់នៅរួច ដោយយកមកនូវប័ណ្ណស្នាក់នៅថ្មីដែលបានពន្យាររយៈពេលស្នាក់នៅរួច។

* ចំពោះអ្នកដែលរយៈពេលស្នាក់នៅដែលត្រូវបានកំណត់ពេលចូលប្រទេសជប៉ុនគឺមិនលើស 3 ខែហើយមិនត្រូវបានផ្តល់ជូនប័ណ្ណស្នាក់នៅ ធនាគារប្រៃសណីយ៍ជប៉ុន/ប៉ុស្តិ៍ប្រៃសណីយ៍មិនអាចបើកគណនីជូនបានឡើយ។

* ចំពោះលោកអ្នកដែលកំពុងធ្វើបែបបទធ្វើបច្ចុប្បន្នភាពលក្ខណៈសម្បត្តិនៃការស្នាក់នៅ/ពន្យាររយៈពេលស្នាក់នៅ សូមយកមកនូវប័ណ្ណស្នាក់នៅថ្មីដែលពន្យាររួច។

■ <u>សូមបង្ហាញកាតសិស្ស/កាតបុគ្គលិកក្រុមហ៊ុនជាដើម។</u>

ចំពោះអ្នកដែលមានលក្ខណៈសម្បត្តិនៃការស្នាក់នៅជា "សិស្សនិស្សិត" "កម្មសិក្សាជំនាញ" នៅពេលបើកគណនី ដើម្បីបញ្ជាក់ការពិតនៃការចូលរៀនឬស្ថានភាពជាក់ស្តែងនៃការបម្រើការងារជាដើម សូមបង្ហាញប័ណ្ណស្នាក់នៅព្រមទាំងកាតសិស្សឬកាតបុគ្គលិកក្រុមហ៊ុនជាដើម។

* យើងអាចនឹងទាក់ទងដើម្បីបញ្ជាក់ទៅក្រុមហ៊ុនឬសាលាអ្នកអំពីការបម្រើការងារឬការចូលរៀនរបស់អ្នក។

■ <u>អាចមានករណីត្រូវចំណាយពេលដើម្បីបើកគណនីបាន។</u>

ពេលជនបរទេសដាក់ពាក្យសុំបើកគណនី ដោយសារត្រូវចំណាយពេលធ្វើការពិនិត្យបញ្ជាក់នានាផ្អែកតាមច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធជាដើម ហេតុនេះអាចមានករណីដែលមិនអាចបើកគណនីបាននៅថ្ងៃទទួលពាក្យហើយត្រូវផ្ញើសៀវភៅគណនីទៅលំនៅដ្ឋានអតិថិជននៅពេលក្រោយ។ ម្យ៉ាងទៀត ករណីខ្លះយើងអាចនឹងបដិសេធមិនបើកគណនីជូន ហេតុនេះសូមជ្រាបទុកជាមុន។

■ ប្រការចង់ឲ្យប្រុងប្រយ័ត្នក្រៅពីនេះ

- ករណីបានពន្យារប័ណ្ណស្នាក់នៅ សូមរួសរាន់ជូនដំណឹងទៅបញ្ជរការិយាល័យដោយយកមកនូវប័ណ្ណក្រោយពន្យាររួចនោះ។ ប្រសិនបើមិនបានជូនដំណឹង អាចនឹងមានការរឹតត្បិតប្រតិបត្តិការជាបណ្តោះអាសន្ន។
- ឯកសារបញ្ជាក់ដែលអ្នកបានបង្ហាញ យើងនឹងស្នើសុំថតចម្លង។
- ករណីជាអ្នកដែលបានជូនដំណឹងថាជាអនិវាសនជន ហើយបានផ្លាស់ប្តូរពីអនិវាសនជនទៅជានិវាសនជន សូមរួសរាន់ជូនដំណឹងទៅបញ្ជរការិយាល័យ។
- ករណីប្តូរទីលំនៅទៅប្រទេសផ្សេងពីប្រទេសជប៉ុនដូចជាធ្វើមាតុភូមិនិវត្តន៍ជាដើម សូមធ្វើបែបបទបិទគណនី។
- ការផ្ទេរឬទិញលក់គណនី(សៀវភៅគណនី/កាតអេធីអឹម) ដែលក្នុងគោលបំណងឲ្យជនទីបីប្រើប្រាស់ គឺជាទង្វើល្មើសច្បាប់។ សូមកុំប្រព្រឹត្តជាដាច់ខាត។